# សេចក្តីប្រកាសពត៌មាន
# ធ្វើឡើងតាមសំណើរបស់ចៅក្រមជាតិនៃ អ.ជ.វ.ត.ក

ចៅក្រមជាតិដែលបានតែងតាំងសម្រាប់ អ.ជ.វ.ត.ក បានចាត់ទុកថា ការសំរេចចិត្តរបស់ចៅក្រមអន្តរជាតិក្នុងការមិនចូលរួមកិច្ចប្រជុំពេញអង្គរបស់ អ.ជ.វ.ត.ក ដែលបានគ្រោងទុកនៅចុងខែមេសានេះនឹងបង្កការពន្យាពេលបន្ថែមទៀតលើដំណើរការជំនុំជម្រះក្តីក្នុងតុលាការនេះ ។

កាលពីថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០០៧ ចៅក្រមជាតិទាំង១៥រូបនៃ អ.ជ.វ.ត.ក បានផ្ញើលិខិតមួយច្បាប់ឆ្លើយតបទៅនឹងលិខិតចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០០៧ របស់សហសេវិកអន្តរជាតិរបស់ពួកគេ ដែលក្នុងលិខិតរបស់ចៅក្រមអន្តរជាតិនេះបានប្រកាសថា ចៅក្រមអន្តរជាតិទាំងអស់នឹងមិនចូលរួមក្នុងសម័យប្រជុំពេញអង្គ ដែលបានគ្រោងទុកធ្វើឡើងនៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៧ នេះ ក្នុងគោលបំណងធ្វើការអនុម័តសេចក្តីព្រាងវិធានផ្ទៃក្នុងរបស់ អ.ជ.វ.ត.ក ដើម្បីឱ្យតុលាការនេះអាចដំណើរការទៅមុខបានឆ្លើយតបតាមការទន្ទឹងរង់ចាំរបស់ជនរងគ្រោះទាំងអស់ ។

ជាការឆ្លើយតបទៅនឹងការលើកឡើងរបស់ចៅក្រមអន្តរជាតិ ចំពោះសំណើទាត់ចោលគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាចេញពីដំណើរការក្តីរបស់ អ.ជ.វ.ត.ក នោះ ចៅក្រមជាតិបានយល់ឃើញថាប្រការនេះមិនស្របទៅនឹងខ្លឹមសារ និងស្មារតីនៃកិច្ចព្រមព្រៀង រវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា (ជាពិសេសត្រង់មាត្រា ២១-៣) និងច្បាប់ស្តីពីការបង្កើត អ.ជ.វ.ត.ក ព្រមទាំងគំនិតដើមនៃការ បង្កើត អ.ជ.វ.ត.ក នោះទេ ។

ចៅក្រមជាតិបានកត់សំគាល់ដែរថា ទាំងចៅក្រមជាតិ និង អន្តរជាតិ ដែលជាសមាជិកនៃគណៈកម្មាធិការត្រួតពិនិត្យឡើងវិញវិធានផ្ទៃក្នុងបានធ្វើការកែសម្រួល និង មានការឯកភាពគ្នាផ្នែកបច្ចេកទេសច្បាប់ លើរាល់ចំណុចខ្វែងគ្នានៃវិធាននេះរួចហើយ ។ ចៅក្រមជាតិយល់ថា ការកំណត់ថ្លៃនៃការចុះបញ្ជីរបស់គណៈមេធាវីមិនមែនជាបញ្ហារបស់វិធានផ្ទៃក្នុងនោះទេ ហេតុដូច្នេះហើយបញ្ហានេះមិនគួរណាជាមូលហេតុនៃការពន្យាពេលការអនុម័តវិធានផ្ទៃក្នុងដូចដែលបានលើកឡើងដោយចៅក្រមអន្តរជាតិក្នុងលិខិតចុះ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៧ នោះឡើយ ។

National Road 4, Chaom Chau Commune, Dangkao District
P.O.BOX 71, Phnom Penh, Cambodia.
Phone: 023 219814 Fax: 023 219841

ចៅក្រមជាតិក៏បានសម្តែងការសោកស្តាយផងដែរ ដែលចៅក្រមអន្តរជាតិបានសម្រេចជ្រើសរើសដាក់ឱសានវាទដល់គណៈមេធាវី ដែលទោះបីជានាពេលកន្លងមកចៅក្រមជាតិបានក្រើនរំលឹកថាការកំណត់ឱសានវាទនេះមិនអាចជំរុញអោយមានផលល្អសម្រាប់ដោះស្រាយបញ្ហានោះឡើយ ។

លើសពីនេះទៅទៀត ចៅក្រមជាតិក៏បានរិះគន់ផងដែរដល់អង្គភាពគាំពារការការពារក្តីនៃ អ.ជ.វ.ត.ក ដែលមិនបានធ្វើសកម្មភាពយ៉ាងសកម្មក្នុងការពិភាក្សា និង ការចរចារជាមួយគណៈមេធាវីដើម្បីរកដំណោះស្រាយណាមួយដែលអាចទទួលយកបានទាំងសងខាង ។

ចៅក្រមជាតិបានបញ្ចប់ក្នុងលិខិតរបស់ពួកគេដោយសង្ឃឹមទុកថា ចៅក្រមអន្តរជាតិនឹងធ្វើការពិចារណាឡើងវិញអំពីការសម្រេចចិត្តរបស់ខ្លួន ក្នុងការចូលរួមកិច្ចប្រជុំពេញអង្គដែលបានគ្រោងទុក ។ ពួកគេបានសង្កត់ធ្ងន់ថាភារកិច្ចដែលចៅក្រមទាំងអស់ ទាំងជាតិ និង អន្តរជាតិបានទទួលពីអង្គការសហប្រជាតិ និង រាជរដ្ឋាភិបាលកម្ពុជាគឺដើម្បីឱ្យ អ.ជ.វ.ត.ក ដំណើរការប្រកបដោយជោគជ័យជាប្រវត្តិសាស្ត្រ ហើយពុំមែនសំរាប់ការបរាជ័យនោះទេ។



National Road 4, Chaom Chau Commune, Dangkao District
P.O.BOX 71, Phnom Penh, Cambodia.
Phone: 023 219814 Fax: 023 219841